ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

TONLE SAP AUTHORITY

អាជ្ញាធរទន្លេសាប

លេខ : ២៣២ ...... អទស

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារចូលរួមពិនិត្យ ផ្ទៀងផ្ទាត់ ធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យដីធ្លី នៃតំបន់បឹងទន្លេសាប ជាមួយក្រុមការងារ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៤ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប
- បានឃើញសេចក្ដីសម្រេចលេខ ០១៤ ដនស/សសរ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ ស្ដីពីការបង្កើតក្រុមការងារពិនិត្យ ផ្ទៀងផ្ទាត់ ធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យដីធ្លី នៃតំបន់បឹងទន្លេសាប របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

អគារលេខ ៥៧៦, ផ្លូវជាតិលេខ ២, សង្កាត់ ចាក់អង្រែក្រោម, ខណ្ឌ មានជ័យ, រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤

# សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងារដើម្បីចូលរួមពិនិត្យ ផ្ទៀងផ្ទាត់ ធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យដីធ្លី នៃតំបន់បឹងទន្លេសាបជាមួយក្រុមការងារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម៖

**១-ខេត្តសៀមរាប**

១- ឯកឧត្តម ហ៊ើល តូនី អនុប្រធានក្កាប់រួម អាជ្ញាធរទន្លេសាប ប្រធាន

២- លោក ម៉ុន ឧស្សី អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ សមាជិក

៣- លោក ខូវ វេងសុខ ប្រធានការិយាល័យធនធានរ៉ែ សមាជិក

៤- លោក កាន់ សម្បត្តិ អនុប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន សមាជិក

**២-ខេត្តបន្ទាយមានជ័យ**

១- ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ អាជ្ញាធរទន្លេសាប ប្រធាន

២- លោក ហេង បូរណា អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស សមាជិក

៣- លោក សុខ មុនី ប្រធានការិយាល័យនីតិកម្ម សមាជិក

៤- លោក ម៉ម សុធា ប្រធានការិយាល័យជីវចម្រុះ សមាជិក

**៣-ខេត្តបាត់ដំបង**

១- ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ អាជ្ញាធរទន្លេសាប ប្រធាន

២- លោក ទិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ សមាជិក

៣- លោក អ៊ូ ទូច ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ សមាជិក

៤- លោក អៀ ច័ន្ទរិទ្ធ អនុប្រធានការិយាល័យនីតិកម្ម សមាជិក

**៤-ខេត្តពោធិ៍សាត់**

១- ឯកឧត្តម ម៉ៅ ហាក់ អនុប្រធាន អាជ្ញាធរទន្លេសាប ប្រធាន

២- លោក យ៉ាន់ សំរិទ្ធ ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ សមាជិក

៣- លោក ពុំ រស្មី អនុប្រធានការិយាល័យសម្របសម្រួលវិវាទ សមាជិក

៤- លោក លេង គឹមលី អនុប្រធានការិយាល័យនីតិកម្ម សមាជិក

**៥-ខេត្តកំពង់ឆ្នាំង**

១- ឯកឧត្តម ខូវ មាស អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប ប្រធាន

២- លោក ហេង សុវណ្ណារ៉ា ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស សមាជិក

៣- លោក ខ្វាន់ ភក្ត្រា អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ សមាជិក

៤- លោក ឃាន ច័ន្ទតារា អនុប្រធានការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី សមាជិក

**៦-ខេត្តកំពង់ធំ**

១- ឯកឧត្តម ជា សុខនី អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប ប្រធាន

២- លោក ឡុក សីលា ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ សមាជិក

៣- លោក អ៊ឹម បញ្ញាវឌ្ឍន៍ ប្រធានការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល សមាជិក

៤- លោក អ៊ុល សុជាតិ ប្រធានការិយាល័យសម្របសម្រួលវិវាទ សមាជិក

**ប្រការ ២._**

ក្រុមការងារមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមសហការជាមួយក្រុមការងារពិនិត្យ ផ្ទៀងផ្ទាត់ ធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យដីធ្លី នៃតំបន់បឹងទន្លេសាប របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រៀបចំប្រជុំ ធ្វើកំណត់ហេតុ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
- ក្រុមការងារអាចស្នើសុំបន្ថែមសមាសភាពតាមតម្រូវការចាំបាច់
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៣ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤ ._**

អនុប្រធានអាជ្ញាធរទន្លេសាប អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានគ្រប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ១២ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៥

**ប្រធាន**

**ថោ-ជេដ្ឋា**

**ចម្លងជូន៖**

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- រដ្ឋបាលខេត្តទាំង៦ ជុំវិញបឹងទន្លេសាប "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ